ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ១៨៨
ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩
សាលដីកា
លេខៈ ៣២ "V"
ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០

# សាលដីកា
## គាមនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

១.លោកស្រី [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រម(របាយការណ៍)

៥.លោក ច័ន្ទ ខឿ ចៅក្រម

### ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted]

### តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ២២៥ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សុផាត ចំពោះសាលដីកាព្រហ្មទណ្ឌលេខ៦៦ ក្រIV "អ.ប" ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន៖

**ជនជាប់ចោទ៖**

១-ឈ្មោះ [redacted] សុផាត ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស មានទីកន្លែងកំណើតនៅភូមិផ្សារលិច ឃុំព្រែកតាកៅ ស្រុកពញាឮ ខេត្តកណ្ដាល មានទីលំនៅមុនពេលឃុំខ្លួននៅភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ) (អ្នកប្តឹងសាទុក្ខ)



Scanned with CamScanner

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៥៨៦៨"ខ" ជ.ឃ.ង ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។

-មានមេធាវីការពារសិទ្ធិលោកស្រី [redacted] សុវ៉ន

**-ជាប់ចោទពីបទ៖** លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចភូមិបាក់ខែងលើ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២-ឈ្មោះ [redacted] វិចារ ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតនៅស្រុកពញាឮ ខេត្តកណ្តាល ទីលំនៅមុនពេលឃុំខ្លួន [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ជានីតិជន ទោសពីមុនគ្មាន។

**-ជាប់ចោទពីបទ៖** លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិបាក់ខែងលើ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ជនរងគ្រោះ ឈ្មោះ [redacted] សុផល ភេទប្រុស អាយុ៤០ឆ្នាំ មានទីលំនៅបច្ចុប្បន្ន [redacted] រាជធានីភ្នំពេញ។

**អំពីអង្គហេតុ៖**

កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨ វេលាម៉ោង១១ និង00នាទី ជនរងគ្រោះឈ្មោះ [redacted] សុផល ភេទប្រុស អាយុ៤០ឆ្នាំ បានបើកម៉ូតូ០១គ្រឿងម៉ាក HONDA C125 ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៥ នៅចំណុចភ្លើងស្តុបខកញ្ញាលីយ៉ុងផាត់ ផ្លូវជាតិលេខ៦ ក្រុមទី២៤ ភូមិបាក់ខែងលើ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ស្រាប់តែមានជនជាប់ចោទឈ្មោះ ព្រុំ វិចារ ភេទប្រុស អាយុ១៨ឆ្នាំ បានបើកម៉ូតូម៉ាកHONDA C125 ពណ៌ក្រហម ស៊េរីឆ្នាំ២០១៨ ស្លាកលេខភ្នំពេញ1GX-2805 ឌុបឈ្មោះ [redacted] សុផាត ភេទប្រុស អាយុ១៧ឆ្នាំ មកអែបខាងឆ្វេងម៉ូតូរបស់ជនរងគ្រោះ ហើយជនជាប់ចោទឈ្មោះ [redacted] សុផាត បានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃរបស់ជនរងគ្រោះបានសម្រេច រួចនាំគ្នាជិះម៉ូតូរត់គេចខ្លួន តែត្រូវបានកម្លាំងនគរបាលដែលល្បាតនៅក្បែរនោះចាប់ខ្លួនបាន។ នៅពេលធ្វើតេស្តទឹកនោមស្វែងរកសារធាតុញៀន ជនជាប់ចោទឈ្មោះ [redacted] វិចារ មានផ្ទុកសារធាតុញៀន។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៥៧ ក្រ១១"ឃ១" ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារដូចតទៅ៖

-ផ្តន្ទាទោសលើជនជាប់ចោទ



Scanned with CamScanner

ក-ឈ្មោះ [redacted] សុផាត ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៣(បី) ឆ្នាំ ពីបទៈ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចភូមិបាក់ខែងលើ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា៣៥៣, មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ខ-ឈ្មោះ [redacted] វិចារ ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៥(ប្រាំ) ឆ្នាំ ពីបទៈ លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច ភូមិបាក់ខែងលើ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា៣៥៣, មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈនាថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុផាត, ជនជាប់ចោទឈ្មោះ [redacted] វិចារ, ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាអសាធារណៈ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩។

ទុកសិទ្ធិឱ្យប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ៩៤ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សុផាត ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៥៧ ក្រ១១"ឃ១" ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

-បានឃើញ សាលដីកាព្រហ្មទណ្ឌ៦៦ ក្រIV"អប" ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ៩៤ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សុផាត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលក្រមលេខ៥៧ ក្រ១១"ឃ១" ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

សាលដីកានេះជំនុំជម្រះ នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិអោយជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩។

ទុកសិទ្ធឱ្យប្ដឹងទាស់ និងសាទុក្ខនៅក្នុងកំណត់ច្បាប់។

-បានឃើញ បណ្ដឹងសាទុក្ខលេខ ២២៥ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សុផាត ដែលប្ដឹងមិនសុខចិត្តនឹងសាលដីកាសាលាឧទ្ធរណ៍លេខ ៦៦ ក្រIV "អ.ប" ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

Scanned with CamScanner

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូលធ្វើសេចក្តីសន្និដ្ឋានសុំថា៖ ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ ដែលតម្កល់សាលក្រមរបស់សាលាដំបូង ទុកជាបានការដដែល គឺមានសំអាងហេតុ និងភស្តុតាងត្រឹមត្រូវតាមច្បាប់ ព្រោះថា៖

-ការប្រព្រឹត្តរបស់ជនជាប់ចោទជាបទល្មើសជាក់ស្តែង។ ម៉្យាងជនជាប់ចោទ បានសារភាពអំពើប្រព្រឹត្តរបស់ខ្លួន និងបក្សពួក និងនៅមុខសាលាឧទ្ធរណ៍សាមីខ្លួន បានសុំតុលាការ មេត្តាជួយបន្ធូរបន្ថយទៅឱ្យខ្លួនតែប៉ុណ្ណោះ ដូចមានក្នុងសំអាងហេតុចំណុចទី៣ នៃសាលដីកាសាលាឧទ្ធរណ៍ស្រាប់។

តំណាងមហាអយ្យការ ស្នើក្រុមប្រឹក្សាជំនុំជម្រះសម្រេច៖

-សុំតម្កល់ សាលដីកាព្រហ្មទណ្ឌលេខ៦៦ ក្រIV "អ.ប" ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

ជនជាប់ចោទឈ្មោះ [redacted] សុផាត បានឆ្លើយថា ខ្ញុំបាទប្តឹងសាទុក្ខមកតុលាការកំពូល ដោយសារខ្ញុំបាទកើតទុក្ខមិនសុខចិត្ត និងសាលដីកាសាលាឧទ្ធរណ៍។ នៅថ្ងៃកើតហេតុឈ្មោះ [redacted] វិចារ បានអោយខ្ញុំលួកដៃយកទូរស័ព្ទ ខ្ញុំក៏ធ្វើតាម តែមិនបានវាយប្រតាយប្រតប់ជាមួយម្ចាស់ទូរស័ព្ទទេ ខ្ញុំធ្វើទៅតាមបញ្ជារបស់គេប៉ុណ្ណោះ។ នៅក្នុងពន្ធនាគារកន្លងមកខ្ញុំបានកែខ្លួនហើយ និងសន្យាថាឈប់ធ្វើបែបនេះទៀតហើយ។

សំណូមពរ សុំឱ្យតុលាការកំពូលមេត្តាសម្រេចបន្ធូរបន្ថយទោសដល់រូបខ្ញុំ ដើម្បីឱ្យខ្ញុំបានចេញទៅរៀនសូត្រឡើងវិញ។

លោកស្រី [redacted] សុវិន មេធាវីការពារជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា៖ រឿងក្តីនេះ ជារឿងក្តីជាក់ស្តែង នាងខ្ញុំសូមនិយាយពីអង្គហេតុដំបូងគឺ ឈ្មោះ [redacted] វិចារ បានបបួលកូនក្តីខ្ញុំទៅទិញខោអាវ ចៃដន្យពេលធ្វើដំណើរ បានឃើញជនរងគ្រោះ ដាក់ទូរស័ព្ទឆ្វេសប្រហែសសំញ៉ែង ធ្វើអោយឈ្មោះ [redacted] វិចារ មានចិត្តលោភលន់ចង់បាន ទើបបញ្ជាឱ្យកូនក្តីខ្ញុំឈ្មោះ [redacted] សុផាត ឆក់ទូរស័ព្ទនោះមក។ កូនក្តីខ្ញុំគាត់នៅក្មេងមិនដឹងអី ក៏បានធ្វើតាមការបញ្ជារបស់ឈ្មោះ [redacted] វិចារ ដោយគ្មានការពិចារណា។ សូមបញ្ជាក់ផងដែរថាកូនក្តីខ្ញុំជាក្មេងស្លូតត្រង់មិនធ្លាប់ប្រព្រឹត្តអំពើល្មើសនោះទេ សូម្បីថ្នាំជក់ក៏មិនធ្លាប់ប្រើប្រាស់ដែរហើយ សមត្ថកិច្ចបានពិនិត្យស្វែងរកសារធាតុញៀន ក៏គ្មានឃើញសារធាតុញៀនក្នុងទឹកនោមទេ។ តុលាការសាលាដំបូង និងសាលាឧទ្ធរណ៍ បានសម្រេចសេចក្តី អោយឈ្មោះ [redacted] សុផាត ជាប់ពន្ធនាគារ០៣(បី) ឆ្នាំ តាមមាត្រា៣៥៣ និង៣៥៧ តែដោយឡែកជនជាប់ចោទជាអនីតិជន តុលាការសាលាដំបូង មិនបានពិចារណា

Scanned with CamScanner

លើមាត្រា១៦០ ពាក់ព័ន្ធនិងមូលទោស ដែលអនុវត្តទៅលើអនីតិជន ដែលមានអាយុចាប់ពី១៤ឆ្នាំឡើងទេ ហេតុដូច្នេះសូមឱ្យតុលាការកំពូលពិចារណាទៅលើអង្គច្បាប់ តាមបញ្ញត្តិមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

សំណូមពរ សូមប្រធានក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណា លើកុមារាឈ្មោះ [redacted] សុផាត ដោយសារ គាត់បានជាប់ពន្ធនាគារ០១ឆ្នាំ ០៧ខែហើយ និងសុំឱ្យតុលាការកំពូលសម្រេចបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ដើម្បីបន្ធូរបន្ថយទោសដើម្បីឱ្យកូនក្តីខ្ញុំឈ្មោះ [redacted] សុផាត បានត្រឡប់ទៅសាលារៀនសូត្រឡើងវិញ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១.យល់ឃើញថា បណ្តឹងសាទុក្ខលេខ២២៥ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សុផាត ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា៤១៧, មាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ដោយប្រកាសពិរុទ្ធភាពជនជាប់ចោទឈ្មោះ [redacted] សុផាត ពាក់ព័ន្ធនិងបទល្មើសលួច យោងតាមមាត្រា៣៥៣ នៃក្រមព្រហ្មទណ្ឌនោះ ជាការត្រឹមត្រូវហើយ ព្រោះថា ជនជាប់ចោទ [redacted] សុផាត ត្រូវបានចាប់ខ្លួន ក្នុងករណីប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ហើយជនជាប់ចោទនេះ ក៏បានសារភាពបង្ហាញអំពីសកម្មភាពបទល្មើស ដែលខ្លួនបានប្រព្រឹត្តរួចហើយដែរ នៅគ្រប់ដំណាក់កាលនីតិវិធី។ ប៉ុន្តែការដែលសាលាឧទ្ធរណ៍សម្រេច តម្កល់សាលក្រមព្រហ្មទណ្ឌ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ដោយផ្តន្ទាទោសជនជាប់ចោទនេះ ពីបទ លួចមានស្ថានទម្ងន់ទោស យោងតាមមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌនោះ ជាការមិនត្រឹមត្រូវទេ ព្រោះថាតាមលទ្ធផលនៃការស៊ើបសួរ ពុំបានរកឃើញអត្ថិភាពនៃអំពើហិង្សា ឬអំពើកាប់គាស់ទម្លុះទម្លាយ ដែលជាស្ថានទម្ងន់ទោស ដូចមានចែងក្នុងចំណុចទី១ និងទី២ នៃមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌនោះឡើយ។

៣-យល់ឃើញថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទ [redacted] សុផាត មានមូលហេតុត្រឹមត្រូវស្របតាមមាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៦៦ក្រIV អ.ប ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មិនត្រឹមត្រូវទេ។

**ហេតុដូច្នេះ**

**សម្រេច**

១-ទទួល បណ្តឹងសាទុក្ខលេខ២២៥ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សុផាត។

២-បដិសេធ សាលដីកាព្រហ្មទណ្ឌលេខ៦៦ ក្រ IV "អប" ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍។

៣-បញ្ជូន សំណុំរឿងព្រហ្មទណ្ឌលេខ១៨៨ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មី។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០។

Scanned with CamScanner